**បទអន្តរាគមន៍**

**ស្តីពីការគ្រប់គ្រង និងអនុវត្តកម្មវិធីអភិវឌ្ឍន៍ជនបទខេត្តស្វាយរៀង**

**សន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ ២០១៥ និងលើកទិសដៅការងារឆ្នាំ ២០១៦**

**របស់ក្រសួងអភិវឌ្ឍន៍ជនបទ**

**ថ្ងៃទី ២៣ ខែកុម្ភៈ ឆ្នាំ ២០១៦**

**ដោយលោក ហុក បូនី ប្រធានមន្ទីរអភិវឌ្ឍន៍ជនបទខេត្តស្វាយរៀង**

ខេត្តស្វាយរៀង ស្ថិតនៅទិសអាគ្នេយ៍នៃរាជធានីភ្នំពេញ តាមផ្លូវជាតិលេខ១ ចម្ងាយ ១២៥គ.ម មានផ្ទៃដី សរុប ២.៩៦៦,៤០ គ.ម$^{២}$ (មិនទាន់គិតផ្ទៃដីកាត់ឲ្យខេត្តព្រៃវែង) ចែកជា ២ក្រុង និង ៦ស្រុក មាន ១២ សង្កាត់ និង ៦៨ឃុំ។ ឆ្នាំ ២០១៥ ប្រជាពលរដ្ឋសរុប ៦១១,៥១១ នាក់ (ស្រី ៣១៥,០០៩ នាក់) ១៣៨.៤១១ គ្រួសារ និងអាត្រាកំណើនប្រជាជនប្រចាំឆ្នាំ ១.៧៣ %។ ប្រជាពលរដ្ឋចាប់ពីអាយុ ១៨ឆ្នាំឡើង មានមុខរបរជាចម្បង ៩៥.២០%ក្នុងនោះវិស័យកសិកម្ម ៧៣.២%,វិស័យផលិតកម្ម ២.១% និងវិស័យសេវាកម្ម ២៤.៧%។

## ១.លទ្ធផលការងារសម្រេចបានក្នុងឆ្នាំ ២០១៥

### ១.១.ការងាររដ្ឋបាលបុគ្គលិក

មន្ទីរអភិវឌ្ឍន៍ជនបទខេត្តស្វាយរៀង មានមន្ត្រីរាជការចំនួន ៦៣ នាក់ ស្ត្រី ១៣ នាក់ មន្ត្រីពុំទាន់តាំងស៊ុបចំនួន ១នាក់(ប្រុស) មន្ត្រីចេញទៅសិក្សានៅក្រៅប្រទេស ៣ នាក់ (ប្រុស) មន្ត្រីជាប់កិច្ចសន្យា ២ នាក់ (ស្ត្រី ១នាក់) ការិយាល័យកិច្ចការរដ្ឋបាលទូទៅបានទទួលលិខិតចូលចំនួន ៧០៧ច្បាប់ និងបញ្ជូនលិខិតចេញចំនួន ៤៣២ច្បាប់។

### ១.២.ការងារផែនការ

-ធ្វើផែនការឆ្លើយតបការធ្វើសមាហរណកម្មថ្នាក់ស្រុក ដែលជាសំណូមពររបស់ផែនការអភិវឌ្ឍន៍ជនបទតាមបណ្តាឃុំ-សង្កាត់ កសាងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍រយៈពេល ៥ឆ្នាំ (២០១៥-២០១៩) និងកសាងកម្មវិធីវិនិយោគ ៣ ឆ្នាំរំកិល (២០១៦-២០១៨ )សម្រាប់អភិវឌ្ឍន៍ខេត្ត និងផែនការសកម្មភាពអនុវត្តឆ្នាំ ២០១៦។

### ១.៣.កិច្ចប្រជុំនានា

-បានដំណើរការប្រជុំជាមួយអង្គការជាតិ និងអន្តរជាតិ ដែលបាន និងកំពុងធ្វើសកម្មភាពអនុវត្តកម្មវិធីទឹកស្អាត និងអនាម័យជនបទនៅក្នុងខេត្តស្វាយរៀង (NGOs Meeting) ចំនួន ៦ លើក។

-ថ្នាក់ដឹកនាំមន្ទីរ រួមជាមួយប្រធាន អនុប្រធានការិយាល័យ និងមន្ត្រី បានចូលរួមសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ ២០១៥ និងទិសដៅអនុវត្តឆ្នាំ ២០១៦ ចំនួន ៥ លើក សិក្ខាសាលាពាក់ព័ន្ធលើការងារពង្រឹងសមត្ថភាពក្នុងការងារអភិវឌ្ឍន៍ជនបទចំនួន ៣៩ លើក និងបានចូលរួមប្រជុំផ្សេងៗចំនួន ១៧៦ លើក។

**១.៤.ការងារកែលម្អផ្លូវជនបទ**

-បានរៀបចំបញ្ជីសារពើភ័ណ្ឌផ្លូវជនបទ និងចុះស្រង់ទិន្នន័យផ្លូវជនបទចំនួន ៦៨៦ ខ្សែ ប្រវែង ២,៥៧០ គ.ម សម្រេចបាន ១០៣ % និងធ្វើបច្ចុប្បន្នភាពផ្លូវជនបទចំនួន ៤៩ ខ្សែ ប្រវែង ២០៤ គ.ម សម្រេចបាន ១១៩ %។

-បានជួសជុលផ្លូវជនបទក្រាលខ្សាច់ភ្នំប្រវែង ៧,៦០០ ម នៅស្រុកស្វាយជ្រំ និងស្រុករំដួល បានថែទាំផ្លូវជនបទជាលក្ខណៈខួប ប្រវែង ១៣,១៨០ ម នៅស្រុកស្វាយជ្រំ សម្រេចបាន ១០០% និងថែទាំផ្លូវជនបទជាប្រចាំប្រវែង ២០,៤០០ ម នៅស្រុករមាសហែក និងស្រុកកំពង់រោទិ៍ សម្រេចបាន ៨៥%។ ទន្ទឹមនឹងនេះ បើកវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពគណៈកម្មការថែទាំផ្លូវជនបទថ្នាក់ឃុំ សង្កាត់ ដើម្បីឆ្លើយតបសមាហរណកម្មឆ្នាំ ២០១៥ ចំនួន ១៣ វគ្គ។

**-សហការជាមួយគម្រោងឧបត្ថម្ភស្បៀងបន្ទាន់÷**

***កម្មវិធីសាច់ប្រាក់ពលកម្ម÷**

-ស្តារឡើងវិញផ្លូវជនបទដីស ដោយប្រើប្រាស់សាច់ប្រាក់ពលកម្ម អនុវត្តបានចំនួន ២៧ គម្រោង ប្រវែង ១៧,៦៩២ម ចំណាយថវិកាចំនួន ២៣៣,៩០៨ដុល្លារ អ្នកទទួលផលចំនួន ១,៧៥៥ គ្រួសារ ស្មើ ៨,៧៣០ នាក់ ស្ត្រី ៥,១៦១នាក់ នៅស្រុករមាសហែក។

***កម្មវិធី Civil Work÷**

-កែលម្អផ្លូវជនបទសាច់ប្រាក់ពលកម្ម ដោយក្រាលគ្រួសក្រហមពីលើ ចំនួន ៣០គម្រោង ប្រវែង ២១,៤៧៤ម ចំណាយថវិកាចំនួន ៤៤៨,៣២១ ដុល្លារ អ្នកទទួលផលចំនួន ១,៧៥៥ គ្រួសារ ស្មើ ៨,៧៣០ នាក់ ស្ត្រី ៥,៧៣១ នាក់ នៅស្រុករមាសហែក និងស្រុករំដួល។

**១.៥.ការងារផ្គត់ផ្គង់ទឹកជនបទ**

-បានសាងសង់អណ្តូងស្នប់អាហ្វ្រិដេស្តថ្មីចំនួន ៩អណ្តូង និងចាក់សាប បានជួសជុលអណ្តូងស្នប់លេខ ៦ ចំនួន ៤៧ អណ្តូង រួមជាមួយការអប់រំ ការប្រើប្រាស់ទឹក និងចងក្រងក្រុមអ្នកប្រើប្រាស់ទឹកអណ្តូងចំនួន ៩ អណ្តូង មាន ៥៤ គ្រួសារ នៅស្រុកស្វាយជ្រំ ស្រុករមាសហែក និងស្រុកកំពង់រោទិ៍ និងចុះបណ្តុះបណ្តាលឆ្លើយតបសមាហរណកម្មថ្នាក់ឃុំ ស្តីពីការស្តុកទឹកទុកផឹកប្រកបដោយសុវត្ថិភាពចំនួន ២២វគ្គ នៅទូទាំងខេត្ត ព្រមទាំងប្រជុំផ្សព្វផ្សាយ និងបណ្តុះបណ្តាល ស្តីពីការងារទឹកស្អាត និងអនាម័យជូនប្រជាពលរដ្ឋចំនួន ១១ វគ្គ នៅស្រុកស្វាយជ្រំ និងស្រុកកំពង់រោទិ៍។

-បានចងក្រង និងប្រមូលទិន្នន័យអណ្តូងគ្រប់ប្រភេទឆ្នាំ ២០១៥ ចំនួន ១៤៣,៤៣១ អណ្តូង។

**១.៦.ការងារសុខភាពជនបទ**

-បានប្រគល់សម្ភារៈបង្គន់គ្រឿងក្រោមចំនួន ២៥០គ្រឿង ដល់ប្រជាពលរដ្ឋចំនួន ២៥០ គ្រួសារ នៅស្រុកស្វាយជ្រំ និងស្រុករមាសហែក និងបានចុះត្រួតពិនិត្យការសាងសង់បង្គន់អនាម័យចំនួន ២៥០ គ្រួសារ។

-បានបើកវគ្គបណ្តុះបណ្តាលស្តីពី ការលើកកម្ពស់អនាម័យជនបទដល់ប្រជាពលរដ្ឋ ដែលទទួលបានបង្គន់ចំនួន ៧វគ្គ បានចុះឆ្លើយតបសមាហរណកម្មផែនការថ្នាក់ស្រុក ស្តីពីការអប់រំប្រើប្រាស់បង្គន់អនាម័យ ជំងឺអេដស៍ និងការសម្អាតលំនៅដ្ឋានចំនួន ៤៣វគ្គ បានចុះតាមដាន និងជំរុញប្រជាពលរដ្ឋឲ្យសាងសង់បង្គន់ និងការប្រើប្រាស់បង្គន់អនាម័យចំនួន ២០ លើក មាន ២៤៦ ខ្នងផ្ទះ អ្នកស្ម័គ្រចិត្តសាងសង់បង្គន់ចាក់ទឹកចំនួន ១១៤បង្គន់។ បានចុះត្រួតពិនិត្យវាយតម្លៃភូមិបញ្ឈប់ការបន្ទោបង់ ពាសវាលពាសកាល (ODF) ចំនួន ២៩ ភូមិ ព្រមទាំងប្រារព្ធទិវាជាតិលើកកម្ពស់អនាម័យជនបទ ១៣ វិច្ឆិកា ចំនួន ២ លើក នៅស្រុករមាសហែក និងស្រុកស្វាយជ្រំ។

**១.៧.ការងារបណ្តុះបណ្តាល និងមជ្ឈមណ្ឌល**

-បានរៀបចំសួនបណ្តុះកូនឈើមួយកន្លែង និងបានបណ្តុះកូនត្នោតចំនួន ២០០០គ្រាប់,កកោះ ១០០០ដើម ,ធ្នង់១០០០ដើម។

-បានបណ្តុះបណ្តាលជំនាញជូនប្រជាកសិករនៅឃុំគោកព្រីង និងឃុំស្វាយចេកចំនួន ៦ វគ្គ គឺការធ្វើជីកំប៉ុស្តិ៍ ២វគ្គ,ការដាំដំណាំបន្លែជាលក្ខណៈគ្រួសារ ២វគ្គ និងដំណាំស្រូវ ២ វគ្គ។ បានបើកវគ្គផ្សព្វផ្សាយ ស្តីពីការបណ្តុះបណ្តាលជំនាញមូលដ្ឋានចំនួន ១ វគ្គ ក្រោមការឧបត្ថម្ភថវិកាពីក្រសួងអភិវឌ្ឍន៍ជនបទ និងបានបណ្តុះបណ្តាលពង្រឹងសមត្ថភាពមន្ត្រីរាជការមន្ទីរអភិវឌ្ឍន៍ជនបទ ស្តីពីការកសាងផែនការ ៥ឆ្នាំ ៣ឆ្នាំរំកិល និង ១ឆ្នាំ ការងារទឹកស្អាតនិងអនាម័យជនបទ ច្បាប់ចរាចរណ៍ផ្លូវគោក សរុបចំនួន ៨វគ្គ។

**-បានបណ្តុះបណ្តាលជំនាញជូនប្រជាកសិករ យុវជន-នារីទាំង ៧ផ្នែក ចំនួន ១៤ វគ្គរួមមាន÷**

| | |
|---|---|
| • ជំនាញកាត់ដេរសំលៀកបំពាក់បុរសនារី | ចំនួន ២វគ្គ សិក្ខាកាមចំនួន ៣២នាក់ ស្រី ២៣ នាក់ |
| • ជំនាញអ៊ុតសក់ និងកែសម្ផស្សន៍ | ចំនួន ២វគ្គ សិក្ខាកាមចំនួន ៣៤ នាក់ ស្រី ៣៤ នាក់ |
| • ជំនាញជួសជុលម៉ូតូគ្រប់ប្រភេទ | ចំនួន ២វគ្គ សិក្ខាកាមចំនួន ៣៤ នាក់ ស្រី ០០ នាក់ |
| • ជំនាញជួសជុលម៉ាន៉ស៊ីនកសិកម្ម | ចំនួន ២វគ្គ សិក្ខាកាមចំនួន ៣៤ នាក់ ស្រី ០០ នាក់ |
| • ជំនាញជួសជុលវិទ្យុម៉ាញ៉េ និងទូរទស្សន៍ | ចំនួន ២វគ្គ សិក្ខាកាមចំនួន ២៩ នាក់ ស្រី ០០ នាក់ |
| • ជំនាញផលិតគ្រឿងសង្ហារឹមពីឬស្សី | ចំនួន ២វគ្គ សិក្ខាកាមចំនួន ៣១ នាក់ ស្រី ០០ នាក់ |
| • ជំនាញសិក្សាភាសារអង់គ្លេស | ចំនួន ២វគ្គ សិក្ខាកាមចំនួន ១០៥ នាក់ ស្រី ៤១នាក់ |
| **សរុបសិក្ខាកាមបានបណ្តុះបណ្តាល** | **ចំនួន ២៩៩ នាក់ ស្រី ៩៨ នាក់** |

-បានចុះតាមដាន និងវាយតម្លៃសិក្ខាកាមដែលបានបញ្ចប់វគ្គចំនួន ៧០ ភូមិ នៅក្រុងស្វាយរៀង ស្រុករំដួល ស្រុកចន្ទ្រា ស្រុករមាសហែក ស្រុកកំពង់រោទិ៍ និងស្រុកស្វាយជ្រំ ជាលទ្ធផលសម្រេចបាន÷

| | |
|---|---|
| • ផ្នែកកាត់ដេរសំលៀកបំពាក់ | ចំនួន ០៦នាក់ បានបើកហាងខ្លួនឯង |
| • ផ្នែកអ៊ុតសក់ និងកែសម្ផស្ស | ចំនួន ០៨នាក់ បានបើកហាងខ្លួនឯង |
| • ផ្នែកជួសជុលម៉ូតូគ្រប់ប្រភេទ | ចំនួន ០៦នាក់ បានបើកហាងខ្លួនឯង |
| • ផ្នែកជួសជុលម៉ាញ៉េ វិទ្យុ និងទូរទស្សន៍ | ចំនួន ០៣នាក់ បានបើកហាងខ្លួនឯង |
| • ផ្នែកជួសជុលម៉ាស៊ីនកសិកម្មគ្រប់ប្រភេទ | ចំនួន ០៤នាក់ បានបើកហាងខ្លួនឯង |
| **សរុបទាំងអស់** | **ចំនួន ២៧ នាក់ ស្រ្តី ១៤ នាក់** |

**១.៨.ការងារអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ**

-បានប្រជុំបើក និងបិទវគ្គឥណទានសាច់ប្រាក់ដល់ក្រុមជួយខ្លួនឯង និងមូលនិធិភូមិចំនួន ៣ភូមិ ក្នុងឃុំ (ម្រាម និងឃុំចន្ទ្រី) មានសមាជិកខ្ចីចំនួន ៣៥ នាក់ ស្ត្រី ២១នាក់ ។

-បានប្រជុំបូកសរុបសមិទ្ធផលអនុវត្តឆ្នាំ ២០១៤ និងលើកទិសដៅឆ្នាំ ២០១៥ បន្តមូលនិធិអភិវឌ្ឍន៍ភូមិចំនួន ២វគ្គ ស្មើ ២២ភូមិ នៅឃុំញរ ឃុំចន្ទ្រី មានសមាជិកចូលរួមចំនួន ១៤៦ នាក់ ស្ត្រី ៥៨នាក់។

-ប្រជុំបូកសរុបសមិទ្ធផលឆ្នាំ ២០១៤ និងលើកទិសដៅឆ្នាំ ២០១៥ បន្តមូលនិធិអភិវឌ្ឍន៍ភូមិ និងក្រុមជួយខ្លួនឯងក្នុងឃុំចន្ទ្រី ស្រុករមាសហែក បានចំនួន ១វគ្គ ដែលមានគណៈកម្មាធិការចូលរួមចំនួន ៣០ នាក់ ស្ត្រី ០២នាក់។

***បានចុះត្រួតពិនិត្យមូលនិធិអភិវឌ្ឍន៍ភូមិ ឃុំ និងក្រុមជួយខ្លួនឯង មានដូចខាងក្រោម÷**

-ធនាគារស្រូវចំនួន ៧ភូមិ មានស្រូវចំនួន ១៥.៦៧២គ.ក្រ (មាន ២ឃុំ ៧ភូមិ) សមាជិកខ្ចីចំនួន ១៣៧នាក់ស្ត្រី ១១៥នាក់

-មូលនិធិអភិវឌ្ឍន៍ភូមិចំនួន ៥ឃុំ ស្មើ ២៥ ភូមិ មានទឹកប្រាក់ចំនួន ២១១.៧៩១.០០០រៀល សមាជិកខ្ចី ចំនួន ៥៩២ នាក់ ស្ត្រី ៣៣៤ នាក់។

-មូលនិធិអភិវឌ្ឍន៍ឃុំចំនួន ៣ឃុំ មានប្រាក់ចំនួន ៧៩.៥៩៥.០០០រៀល អ្នកខ្ចីចំនួន ១១៤នាក់ ស្ត្រី ៨៩នាក់។

-ក្រុមជួយខ្លួនឯងមាន ២២ភូមិ ៣ឃុំ មានប្រាក់ចំនួន ១៧៨.៧១០.០០០រៀល អ្នកខ្ចីចំនួន ៥៦២ នាក់ ស្ត្រី ៣៧៦នាក់។

**១.៩.ការងារអភិវឌ្ឍន៍សហគមន៍**

-បានបណ្តុះបណ្តាលពង្រឹងសមត្ថភាពយុវជនស្តីពី អាជីវកម្មខ្នាតតូច គោលគំនិតនៃការអភិវឌ្ឍសហគមន៍ មូលដ្ឋានគ្រឹះនៃការធ្វើផែនការអាជីវកម្ម ជំនាញគ្រូបង្គោលចំនួន ២៨វគ្គ។ ពង្រឹងសមត្ថភាពគ.អ.ភ ស្តីពី គោលគំនិតនៃការអភិវឌ្ឍសហគមន៍ ចំនួន ២វគ្គ និងតួនាទីភារកិច្ចរបស់គណៈកម្មាធិការអភិវឌ្ឍន៍ភូមិ ចំនួន ២០វគ្គ និងផែនការសកម្មភាពអភិវឌ្ឍន៍ភូមិចំនួន ១២វគ្គ។

-បានជីកស្រះសហគមន៍ទំហំ(៨មx៦ម)ចំនួន ២០ស្រះសម្រាប់ស្រោចស្រព បន្លែ និងចិញ្ចឹមត្រី នៅស្រុករមាសហែក គាំទ្រដោយអង្គការ Child Fund និងអង្គការ CCPCR គាំទ្រវគ្គគ្រូបង្គោល ១វគ្គ ចុះចែកមេគោចំនួន ២០ក្បាល ស្មើ ២០គ្រួសារ ដល់ក្រុមជួយខ្លួនឯងនៅស្រុកកំពង់រោទិ៍ ។

-បានរៀបចំសមាសភាព គ.អ.ភ ឡើងវិញ ចំនួន ១៨៩ភូមិ នៅស្រុកស្វាយជ្រំ ៣០ភូមិ ស្រុករមាសហែក ៤៨ភូមិ ស្រុកចន្ទ្រា ១០ភូមិ ស្រុកកំពង់រោទិ៍ ៣៥ភូមិ ស្រុករំដួល ៤៣ភូមិ និងក្រុងបាវិត ២៣ភូមិ។

-បានចុះត្រួតពិនិត្យ តាមដាន គណៈកម្មាធិការអភិវឌ្ឍន៍ភូមិ គ.អ.ភ ចំនួន ៣៥ លើកនៅទូទាំងខេត្ត និងពិនិត្យមើលការសាងសង់ទីស្នាក់ គ.អ.ភ នៅស្រុកស្វាយជ្រំ និងបានធ្វើបច្ចុប្បន្នភាពស្ថិតិ គ.អ.ភ ទូទាំងខេត្ត។

-បានបោះពុម្ពសៀវភៅ ០២ក្បាល ស្តីពី "មូលដ្ឋានគ្រឹះនៃការធ្វើផែនការអាជីវកម្ម និងការចុះបញ្ជីចំណូល ចំណាយ" និង "ជំនាញគ្រូបង្គោល"។

**១.១០.ការងារយេនឌ័រ**

-បានចូលរួមប្រជុំបូកសរុបលទ្ធផលការងារ គណៈកម្មាធិការទទួលបន្ទុកស្ត្រី និងកុមារ(គ.ក.ស.ក) ខេត្តរៀងរាល់ខែ នៅសាលាខេត្តស្វាយរៀង ចំនួន ១២ លើក។

-ដោយមានការយកចិត្តទុកដាក់ពីឯកឧត្តមរដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ គណៈអភិបាលខេត្ត និងថ្នាក់ដឹកនាំមន្ទីរអភិវឌ្ឍន៍ជនបទ មន្ទីរបានរៀបចំទិវាសិទ្ធនារីលើកទី ១០៤ ៨ មីនា ឆ្នាំ ២០១៥ បាន ឧបត្ថម្ភដល់នារីចំនួន ១៥នាក់ ក្នុងនោះម្នាក់ៗទទួលបានសារ៉ុង ១ និងថវិកា ២០ ០០០រៀល ជាអំណោយ របស់មន្ទីរផ្ទាល់ និងអំណោយដ៏ថ្លៃថ្លារបស់ឯកឧត្តមរដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ ចំនួន ១៥នាក់ ក្នុង នោះម្នាក់ៗទទួលបានសារ៉ុង ១ និងថវិកា ១៥០ ០០០រៀល។

**២.សកម្មភាពសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍**

-បានប្រជុំ (NGOs Meeting)២ខែម្តងចំនួន ៦លើក ដើម្បីបង្ហាញពីសកម្មភាពរបស់អង្គការ នីមួយៗ ទីតាំងធ្វើសកម្មភាពបញ្ហាប្រឈម និងគៀងគរកថវិកា ក្នុងគោលបំណងសម្រេចឲ្យបាននូវ ផែនការសកម្មភាពដែលមន្ទីរបានលើកឡើង។

-បាន និងកំពុងសហការជាមួយអង្គការ Child Fund អង្គការ CFED អង្គការ SNV អង្គការ IDE អង្គការសន្តិសេនា អង្គការកូនក្មេង អង្គការស្អាតកម្ពុជា អង្គការវឌ្ឍនភាព អង្គការការពារសិទ្ធិកុមារ អង្គការ អភិវឌ្ឍន៍កសិកម្មខ្នាតតូច អនុវត្តលើសកម្មភាពការរៀបចំគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ និងកម្មវិធីទឹកស្អាត និងអនាម័យជនបទ ចំនួន ៤៥ ឃុំ ក្នុង ៦ស្រុក។

**៣.អំពីចំណុចខ្លាំង និងបញ្ហាប្រឈម**

**៣.១.ចំណុចខ្លាំង**

-មានការគាំទ្រសកម្មភាព និងការយកចិត្តទុកដាក់ ផ្តល់អនុសាសន៍ណែនាំពីថ្នាក់ដឹកនាំក្រសួង អភិវឌ្ឍន៍ជនបទ នាយកដ្ឋានជំនាញ ក្រុមប្រឹក្សាខេត្ត គណៈអភិបាលខេត្ត អភិបាលស្រុក លោកមេឃុំ ចៅ សង្កាត់ គណៈកម្មាធិការអភិវឌ្ឍន៍ភូមិ ធ្វើឲ្យការងារអភិវឌ្ឍន៍ ទទួលបានលទ្ធផលគួរជាទីមោទនៈ។

-កំណត់តំបន់គោលដៅធ្វើសកម្មភាពត្រឹមត្រូវ ក្នុងគោលបំណងបម្រើផលប្រយោជន៍ជូនប្រជាជន ឲ្យទទួលបានសេវាផ្សព្វផ្សាយ ផ្គត់ផ្គង់ពាក់ព័ន្ធលើស្ថានភាពទឹក និងអនាម័យជនបទ ដើម្បីចូលរួមលើក កម្ពស់ជីវភាពរស់នៅ។

-រាល់ការងារអភិវឌ្ឍន៍ជនបទ សុទ្ធតែបានទទួលស្គាល់អបអរសាទរចូលរួមទាំងស្មារតី និងសម្ភារៈ ពីប្រជាកសិករ និងភាពជាម្ចាស់កាន់តែត្រូវបានពង្រឹង និងលើកកម្ពស់។

-រាល់សមិទ្ធផលបានកសាងឡើង ជាលទ្ធផលមួយជំរុញឲ្យជីវភាពប្រជាកសិករ កែសម្រួលបន្តិច ម្តងៗ និងឈានទៅមានសុភមង្គល។

-ផែនការសកម្មភាព ឬដំណាក់កាលនៃការអនុវត្តសកម្មភាព ត្រូវបានអជ្ញាធរមូលដ្ឋានចូលរួម អនុវត្តគម្រោងយ៉ាងពេញចិត្ត និងធ្វើឲ្យគម្រោងទទួលបានជោគជ័យ។

-សហការណ៍ជាមួយអង្គការជាតិ អន្តរជាតិ សង្គមស៊ីវិល វិស័យឯកជន និងប្រជាពលរដ្ឋបានចូល រួមយ៉ាងសកម្មក្នុងការអភិវឌ្ឍជនបទ។

### ៣.២.បញ្ហាប្រឈម

-សមត្ថភាពមន្ត្រីរាជការមួយចំនួនពាក់ព័ន្ធជាមួយជំនាញនៅមានកម្រិត។

-ខ្វះខាតថវិកាដើម្បីឆ្លើយតបទៅនឹងផែនការសកម្មភាពជាអាទិភាព របស់ក្រុមប្រឹក្សាឃុំសង្កាត់។

-ជីវភាពប្រជាកសិករក្រីក្រនៅជនបទ ក៏ជាមូលហេតុមួយធ្វើឱ្យការស្ម័គ្រចិត្តចូលរួមបញ្ចេញកម្លាំងក្នុងសកម្មភាពអភិវឌ្ឍន៍មានកម្រិត ចំណាកស្រុកច្រើនដោយរង់ចាំពឹងផ្អែកពីខាងក្រៅ។

-យុវជន យុវនារី ពេញវ័យ ពីអាយុ ១៥-១៨ ឆ្នាំ នៅតាមវិទ្យាល័យ និងអនុវិទ្យាល័យ បានបោះបង់ការសិក្សានៅថ្នាក់កម្រិតមូលដ្ឋាន ដើម្បីទៅបម្រើការងារជាកម្មករនៅតាមរោងចក្រ។

-ប្រជាជនមួយចំនួនពុំទាន់ធ្វើជាម្ចាស់ ក្នុងការប្រើប្រាស់នូវសក្តានុពលនៃកំលាំង និងធនធានដើម្បីដោះស្រាយរាល់បញ្ហារបស់ខ្លួនដោយខ្លួនឯង ពោលគឺនៅតែពឹងផ្អែកពីខាងក្រៅ។

- គោយន្តកង់ដែកចរាចរណ៍លើផ្លូវជនបទ ក្រាលក្រួសឬខ្សាច់ភ្នំ ដែលបណ្តាលឱ្យខូចផ្លូវ។

## ៤.ទិសដៅការងារសម្រាប់អនុវត្ត ឆ្នាំ ២០១៦

-ចុះជំរុញកសិករប្រើប្រាស់ឱ្យអស់នូវសក្តានុពល នៃការងារបង្កបង្កើនផលផ្នែកកសិកម្ម។

-ជួសជុលផ្លូវដោយក្រាលកៅស៊ូប្រវែង ១២គ.ម ក្រាលខ្សាច់ភ្នំប្រវែង ១០គ.ម និងថែទាំផ្លូវជនបទជាលក្ខណៈខួបប្រវែង ១៥ គ.ម ថែទាំផ្លូវជាប្រចាំប្រវែង ២២ គ.ម និងបន្តចុះស្រង់ទិន្នន័យផ្លូវជនបទចំនួន ៣៦ខ្សែ ប្រវែង ៨៥ គ.ម និងធ្វើបច្ចុប្បន្នភាពផ្លូវជនបទចំនួន ៣២ខ្សែ ប្រវែង ១៧៦ គ.ម។

-សាងសង់អណ្តូងអាហ្វ្រីដេសចំនួន ១០អណ្តូង ជួសជុលអណ្តូងស្នប់លេខ ៦ ចំនួន ៥០អណ្តូង អប់រំពីអនាម័យនៃការប្រើប្រាស់ទឹកចំនួន ១៩ វគ្គ និងចុះអប់រំផ្សព្វផ្សាយកម្មវិធីធ្វើទឹកឱ្យស្អាត រួមជាមួយការធ្វើតេស្តគុណភាពទឹក និងចងក្រងក្រុមប្រើប្រាស់ទឹកចំនួន ២៥ អណ្តូង។

-ផ្តល់បង្គន់គ្រឿងក្រោមចំនួន ២៥០ គ្រឿង អប់រំប្រជាជនអំពីសុខភាពចំនួន ១៦ វគ្គ ចំណេះដឹងអេដស៍ ចំនួន ៦វគ្គ អប់រំអំពីការប្រើប្រាស់បង្គន់អនាម័យចំនួន ១៦វគ្គ និងអប់រំគ្រួសារទទួលបានបង្គន់ចំនួន ២៥០គ្រួសារ។

-បណ្តុះបណ្តាលពង្រឹងសមត្ថភាព គ.អ.ភ ចំនួន ៤២ វគ្គ ធ្វើបច្ចុប្បន្នភាព គ.អ.ភ ចំនួន ៥០ភូមិរួមជាមួយ និងការចុះត្រួតពិនិត្យសកម្មភាព គ.អ.ភ ចំនួន ៦៩០ ភូមិ និងបណ្តុះបណ្តាលផ្នែកជំនាញកសិកម្មចំនួន ៦វគ្គ។

-ពង្រឹងសហគមន៍ឥណទានប្រាក់ និងក្រុមជួយខ្លួនឯងចំនួន ៤៥ ភូមិ ស្មើ ៥ឃុំ ធនាគារស្រូវចំនួន ៧ ភូមិ ២ឃុំ និងមូលនិធិអភិវឌ្ឍន៍ឃុំចំនួន ៣ឃុំ ឱ្យមានដំណើការល្អ។

-ជំរុញ និងចលនាយុវជនយុវនារី ដែលពុំមានលទ្ធភាពបន្តការសិក្សានៅវិទ្យាល័យ ឱ្យចូលរៀននូវមុខជំនាញ ៧មុខ នៅមជ្ឈមណ្ឌលបណ្តុះបណ្តាលជំនាញមូលដ្ឋានខេត្ត និងចុះត្រួតពិនិត្យវាយតម្លៃសិក្ខាកាមបានបញ្ចប់វគ្គរួចនៅតាមសហគមន៍។

-ធ្វើការបណ្តុះបណ្តាលមន្ត្រីរាជការក្នុងមន្ទីរ អំពីជំនាញនៃការសម្របសម្រួលក្នុងការងារអភិវឌ្ឍន៍សហគមន៍ក្នុង ១ខែ ២ដង សរុប ២៤លើក។

-រៀបចំទិវាជាតិអនាម័យជនបទ ១៣ វិច្ឆិកា ចំនួន ១លើក។

-សហការជាមួយគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ កប់គ្រាប់ត្នោត និងដាំកូនឈើអមសងខាងផ្លូវជនបទ ដែលបានជួសជុល។

-សហការណ៍ជាមួយអង្គការដៃគូអភិវឌ្ឍន៍នានា លើកម្មវិធីអភិវឌ្ឍន៍សហគមន៍ កម្មវិធីទឹកស្អាត និងអនាម័យជនបទ រួមជាមួយការគៀងគរ និងរកថវិកា (រៀបចំ NGO Meeting)។

**៥.វិធានការសំខាន់ៗដើម្បីសម្រេចទិសដៅ**

១/បង្កើនសមត្ថភាពជំនាញបច្ចេកទេស ដល់មន្ត្រីរាជការជាបន្តទៅទៀត។

២/យកចិត្តទុកដាក់ពង្រឹងរចនាសម្ព័ន្ធ គណៈកម្មាធិការអភិវឌ្ឍន៍ភូមិ ខ្សោយ និងមធ្យមឱ្យចេះពីរបៀបរបបធ្វើការងារ ដើម្បីដឹកនាំប្រជាជនឱ្យរួចផុតពីភាពអាស្រ័យពីខាងក្រៅ។

៣/យកចិត្តទុកដាក់ពង្រឹងគោលជំហរ ឆន្ទៈដល់ប្រជាពលរដ្ឋនៅជនបទដើម្បីចូលរួមគាំទ្រ សហការយ៉ាងសកម្មគ្រប់សកម្មភាព ក្នុងការងារអភិវឌ្ឍន៍ឱ្យសម្រេចទៅតាមផែនការដែលបានដាក់ចុះ ឈានទៅធានាស្ថេរភាពនៃគម្រោងទៅអនាគត និងយកចិត្តទុកដាក់ពង្រឹងការងារ តាមដានត្រួតពិនិត្យជាប្រចាំ លើគ្រប់មុខជំនាញ ដើម្បីមានលទ្ធភាពដោះស្រាយបានទាន់ពេលវេលា រាល់បាតុភាពអសកម្មដែលអាចកើតមានឡើងជាយថាហេតុ។

៤/ពង្រីកការទំនាក់ទំនងល្អជាមួយស្ថាប័នរដ្ឋនានា ដែលពាក់ព័ន្ធ និងពីអាជ្ញាធរគ្រប់ជាន់ថ្នាក់ រួមជាមួយប្រជាពលរដ្ឋ ដើម្បីឱ្យការអនុវត្តទទួលបានប្រសិទ្ធភាព។

៥/ពង្រីកកិច្ចសហប្រតិបត្តិការ ជាមួយអង្គការជាតិ អន្តរជាតិនានា លើកិច្ចអភិវឌ្ឍតាមសហគមន៍។

**៦.សេចក្ដីសន្និដ្ឋាន**

សកម្មភាពគ្រប់ផ្នែក ដែលបានត្រៀមបំរុងទុកជាមុន នឹងត្រូវអនុវត្តប្រកបដោយស្មារតីទទួលខុសត្រូវ និងមានឆន្ទៈ ដើម្បីឆ្លើយតបទៅនឹងសកម្មភាពតម្រូវការរបស់សហគមន៍ និងសង្ឃឹមថាភាពក្រីក្រនៅតាមសហគមន៍ និងត្រូវបានកាត់បន្ថយជាបណ្ដើៗ។

**៧.សំណូមពរ**

មន្ទីរអភិវឌ្ឍន៍ជនបទខេត្តស្វាយរៀង សូមស្នើក្រសួងអភិវឌ្ឍន៍ជនបទ ជួយពង្រឹងឬបំប៉នសមត្ថភាពមន្ត្រីបន្ថែមទៀតនូវការងារបច្ចេកទេសនានា ដូចជាការងារអប់រំសុខភាព និងអនាម័យជនបទ ការងារអភិវឌ្ឍន៍សហគមន៍ សេដ្ឋកិច្ចជនបទ ផ្លូវជនបទ និងទឹកស្អាតជាដើម ឬការធ្វើទស្សនៈកិច្ចសិក្សាក្នុង និងក្រៅប្រទេស។